ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៧៤

ចុះថ្ងៃទី៣០ខែមិនាឆ្នាំ២០០១

សាលដីកា

លេខ : ៣៨

ចុះថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ:-

១-ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២-លោក ខៀល ចួន ជាចៅក្រមរបាយការណ៍

៣-លោក ប្រាក់ គីមសាន ជាចៅក្រម

៤-លោក ជីវ កេង ជាចៅក្រម

៥-លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី ឃុត សុគន្ធា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ០៤ "ឃ" ចុះថ្ងៃទី ១១-០១-០១ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ ៣៩៨ ចុះថ្ងៃទី០៩-៦-០០ របស់ សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ពេង អ៊ួន អាយុ ៤៨ឆ្នាំ មុខរបរប្រធានក្រុមហ៊ុនយ៉ើត្រី ទីលំនៅផ្ទះលេខ ១៩ ផ្លូវ ៣៨០ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ផ្ទេរសិទ្ធិអោយឈ្មោះ ស៊ឹង រ័ក្ស, អ៊ុក ទូច និង លី វិសាលមេធាវីចិត្តវិជ្ជិកា

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ គុច សារុន អាយុ ៥២ ឆ្នាំ មុខរបរលក់ដូរ ទីលំនៅភូមិ២០ឧសភា ឃុំស្វាយទៀប ស្រុកស្វាយទៀប ខេត្តបាត់ដំបង ។

មេធាវី : លោក ទូត លុច

កម្មវត្ថុបណ្តឹង :ប្តឹងទាមទារដីយ៉ើត្រីទំហំ២០មគុណ៤០ម និងទារថ្លៃសំណង់

បានឃើញបណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ៥-៣-០១ របស់អ្នកស្រី ពេង អ៊ួន ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ០៤ "ឃ" ចុះថ្ងៃទី១១-០១-០១ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៧៤ចុះថ្ងៃទី៣០-៣-០១របស់តុលាការកំពូល ។

១_តាមពាក្យបណ្តឹងចុះថ្ងៃទី២២_៤_៩៩ អ្នកស្រី ចៀ អ៊ិន, ច្រាំ វណ្ណៈ, កែវ ព្រំ តុប សារឿន, ទេព ម៉ៅ, ឡាយ យ៉េង, លី គីមសាន, វង្ស ខៀវនិង ន ប៊ុនរិទ្ធិ ថា:_ ពួកខ្លួនទាំងអស់គ្នា មិនសុខចិត្តនឹងលោក តុប សារុន ជាសមាជិកភាគហ៊ុន នៃ ក្រុមហ៊ុនអាជីវ_កម្មនេសាទបានលក់ដីស្តង់ត្រីទំហំ ៤០ម គុណ ២០ម ស្ថិតនៅដីឡូត៍លេខ១ ក្រុម៣ ភូមិប៉ាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យទៅអោយជនផ្សេងទៀត បំពានទៅលើសេចក្តីសំរេចលេខ ៣៤០សសរ ចុះថ្ងៃទី ០២_៩_៩១ របស់ខេត្តបន្ទាយមានជ័យ ដែលសេចក្តីសំរេចនេះបានអោយអ្នកស្រី ចៀ អ៊ិនព្រមទាំងសមាជិកភាគហ៊ុនឯទៀតកាន់កាប់សម្រាប់ធ្វើអាជីវកម្ម ។ ម្យ៉ាងវិញទៀតបានធ្វើប័ណ្ណកម្មសិទ្ធិជារបស់ផ្ទាល់ខ្លួន និង លក់ដីអោយទៅអ្នកផ្សេងដោយពុំមានការយល់ព្រមពីអ្នកស្រី ចៀ អ៊ិន ជាប្រធាន និង សមាជិក_ឯទៀត និង តាមសំឡូមពរបន្ថែមចុះថ្ងៃទី ១៦_៩_៩៩ របស់ឈ្មោះ ទេព ម៉ៅ និង _ វង្ស ខៀវ តំណាងផ្ទេរសិទ្ធិថា:_

១_សុំបដិសេធប័ណ្ណសំគាល់សិទ្ធិលេខស្ជេ ០៣៩៩ ចុះថ្ងៃទី ១៧_៧_៩៨

២_សុំបដិសេធប័ណ្ណសំគាល់សិទ្ធិលេខស្ជេ ០៣៩៩ ចុះថ្ងៃទី ១៧_១២_៩៨

៣_សុំបដិសេធប័ណ្ណសំគាល់សិទ្ធិលេខស្ជេ ០៥៦៦ ចុះថ្ងៃទី ១៥_៣_៩៩

៤_ទាមទារដីទំហំ ៤០ម គុណ ២០ម "ដីទំនាស់" មកជាកម្មសិទ្ធិរបស់ក្រុមហ៊ុនវិញ ។

៥_ទាមទារអោយសងថ្លៃសំណង់រោងស្តង់ត្រីគិតជាប្រាក់១៧០០.០០០បាត

៦_ទាមទារអោយសងការខូចខាត និង ចំណាយលើសេវាច្បាប់ផ្សេងពុចំនួន ១០.០០០ដុល្លាអាមេរិក ។

៧_សុំអោយរឹបអូសទ្រព្យសម្បត្តិ តុប សរុន ធានាសំណង ហើយបើរឹងរូស សុំដាក់គុកបង្ខំរូបកាយ ។

២_តាមលិខិតលេខ ៨៩០ ខបជ ចុះថ្ងៃទី២៧_៧_៩៩ របស់សាលាខេត្តបន្ទាយមានជ័យ "ជាតតិយជនខាងដើមចោទ" ថា:_ មន្ទីរកសិកម្មខេត្តបានប្រគល់ដីទំហំ ៤០ម គុណ ២០ម អោយអ្នកស្រី ចៀ អ៊ិនជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងធ្វើឃ្សើត្រីស្រស់ និង កែច្នៃដោយមានសៀវភៅបន្ទុកជួលឃ្សើត្រីនេសាទ សម្រាប់រយះពេល ២ឆ្នាំគិតចាប់ពីថ្ងៃទី_០១_៩_៩១ របស់គណធម្មាធិការខេត្ត ។ នៅថ្ងៃទី១២_៦_៩៣ ខេត្តបានចេញសេចក្តីសំរេចលេខ ១៥០ សសរ ចុះថ្ងៃទី ១២_៦_៩៥ ហើយអនុញ្ញាតអោយឈ្មោះ ចៀ អ៊ិន បន្តធ្វើអាជីវកម្មរយះពេល២ឆ្នាំបន្តទៀត រហូតដល់ថ្ងៃទី ២០_៦_៩៥ ។ ប៉ុន្តែដោយភាពមិនប្រក្រតីរបស់មន្ត្រីគ្រប់គ្រងមួយចំនួនក្នុងគោលបំណងបែងចែកផលប្រយោជន៍លើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋបានបង្កអោយឈ្មោះ តុប សារុន បន្លំធ្វើពាក្យសុំកាន់កាប់ដីនេះជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ ដូច្នេះខេត្តសុំបដិសេធឈ្មោះ តុប សារុន ជាកម្មសិទ្ធិករលើដីនេះ និង ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលើដីនោះ ។

ហើយប្រគល់ដីនោះមកអោយអាជ្ញាធរខេត្ត ដើម្បីគ្រប់គ្រងជាទ្រព្យសម្បត្តិឯកជនរបស់ខេត្តវិញ ។

បានឃើញសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២៤-០២-០០ របស់តុលាការខេត្តបន្ទាយ-មានជ័យ ដែលសំរេចដូចតទៅ:-

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២២-៤-៩៩ និង បណ្តឹងបន្ថែមចុះថ្ងៃទី ២៧-៧-៩៩ របស់ភាគីតំណាងក្រុមហ៊ុនជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-បដិសេធឈ្មោះ គុប សារុន ចេញពីប័ណ្ណសំគាល់សិទ្ធិលេខ សេ៨ ០៣៩៩ ចុះ-ថ្ងៃទី ១៧-៧-៩៨ និង ឈ្មោះ ឈិន យុយាង ពីប័ណ្ណសំគាល់សិទ្ធិលេខ សេ៨ ០៣៩៥ · ចុះថ្ងៃទី ១៧-១២-៩៩ ព្រមទាំងឈ្មោះ សេង ងួនពីប័ណ្ណសំគាល់សិទ្ធិលេខសេ៨ ០៥៦៦ ចុះថ្ងៃទី-១៥-៣-៩៩ ។ ដីដែលមានប័ណ្ណសំគាល់សិទ្ធិខាងលើនេះ ដែលមានទទឹង ២០ម បណ្តោយ ៤០ម បង្វែរប្រគល់ជូនជាសម្បត្តិអចលនៈវត្ថុ ទ្រព្យឯកជនរបស់អាជ្ញាធរខេត្ត ដើម្បីគ្រប់គ្រងក្រោមសិទ្ធិរបស់ខេត្ត ។

ទុកសិទ្ធិអោយក្រុមហ៊ុន យឿត្រី ហៀ អ៊ួន បន្តការទំនាក់ទំនងរបស់ក្រុមហ៊ុនជាមួយអាជ្ញាធរខេត្តបានជាដរាបផ្សារភ្ជាប់នឹងសេចក្តីបញ្ជីជាលាយល័ក្ខអក្សរ ចុះថ្ងៃទី ១៨-៨-៩៨ របស់ឯកឧត្តម ឆាយ សារ៉េត អតីតៈ អភិបាលរងទី១ខេត្ត អាណត្តិទី១ ។

៣-លោក គុប សារុន ជាចុងចម្លើយ ដែលបានរុះរើធ្វើអោយខូចខាតបាត់បង់នូវរោងសំណង់យឿត្រីរបស់ក្រុមហ៊ុន ត្រូវបង្គាប់អោយសងប្រាក់ចំនួន ៥០.០០០.០០០រៀល "ហាសិបលានរៀល" និង អោយសងជម្ងឺចិត្ត ២.០០០ដុល្លាអាមេរិកដល់ក្រុមហ៊ុន ដើមចោទ · ទាមទារលើសពីនេះបដិសេធ ។

៤-អោយភាគីចុងចម្លើយសងប្រាក់ប្រដាប់ក្តី ៧.០០០រ,០០ ដែលដើមចោទបានបង់ទុករួចហើយនោះទៅដើមចោទវិញ និង អោយបង់ពន្ធសមាមាត្រក្នុងអត្រា១ភាគរយលើប្រាក់សំណង ៥០.០០០.០០០រៀល តាមបញ្ញត្តិច្បាប់ ។

សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខគូភាគី ទុកសិទ្ធិប្តឹងឧទ្ធរណ៍ពីរខែគិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍របស់លោក គុប សារុន ចុះថ្ងៃទី ២២-៣-០០ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីកាលេខ ០៤ "ឈ" ចុះថ្ងៃទី ១១-០១-០១ របស់ សាលាឧទ្ធរណ៍ ដែលសំរេចដូចតទៅ :-

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ គុប សារុន ចុះថ្ងៃទី ២២-០៣-០០ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលស្គាល់លិខិតថណាយក្តីរបស់មេធាវីដើមចោទចុះថ្ងៃទី ២៩-៦-០០ ទុកជា

ត្រឹមត្រូវតាមច្បាប់ ។

៣_បដិសេធសាលក្រមលេខ ៣៤ ចុះថ្ងៃទី ២៤_០២_០០ របស់តុលាការខេត្តបន្ទាយមានជ័យចោលជាអសារបង់ ។

៤_ទទួលពាក្យបណ្តឹងរបស់អាជ្ញាធរខេត្តលេខ ១៣៦៣ខបជ ចុះថ្ងៃទី២៥_០៨_០០ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

៥_ប្រគល់ដីទំនាស់ដូចមានបណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខបជ០០១៧៣៦ ចុះថ្ងៃទី១៧_៧_៩៨ ទៅអោយឈ្មោះ គុប សារុន ដើម្បីជាកម្មសិទ្ធិ និង ចាត់ចែងតាមច្បាប់តទៅ ។

៦_បង្គាប់អោយ គុប សារ៉ុន សងថ្លៃសំណងយឿត្រីជាប្រាក់ស្មើនឹង ៤០.០០០.០០០រៀ "សែសិបលានរៀល" ទៅអោយក្រុមហ៊ុន(អាជីវកម្ម)យឿត្រីដែលមានមេធាវី ឡាយ សំណាង ជាតំណាង ដើម្បីបែងចែកតាមភាគហ៊ុននៃសមាជិកភាគហ៊ុនម្នាក់ៗ នៃ ក្រុមអាជីវកម្ម ។ សំណូមពរលើសពីនេះបដិសេធចោល ។

៧_បង្គាប់អោយក្រុមហ៊ុនអាជីវកម្មយឿត្រីរុះរើរោងនៅលើដីទំនាស់ និង បែងចែកតាមភាគហ៊ុននីមួយៗ នៃ ក្រុមអាជីវកម្ម ។

៨_កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ១៣.០០០រ.០០ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០រ.០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រ.០០ រង្វាន់អ្នកប្រគល់ដីកាកោះ ៥.០០០រ.០០ ចំណាយលើអាជ្ញាធរតុលាការ _ ៥.០០០រ.០០ ។ កាលបើផុតបណ្តឹងសាទុក្ខអោយគុបសារុនបង់ពន្ធសមាមាត្រ១ភាគរយនៃចំនួនទឹកប្រាក់ក្នុងចំណុចទី៦ នៃសាលដីកានេះ ។ ប្រាក់ពន្ធសមាមាត្រនេះត្រូវដាក់ចូលក្នុងថវិការដ្ឋ ៨០ភាគរយ និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ភាគរយ ។

៩_សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី និង តតិយជន បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ០៥_៣_០១ របស់ឈ្មោះ ហៀ អ៊ួន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណារបស់តំណាងក្រុមហ៊ុន ហៀ អ៊ួន ចុះថ្ងៃទី ០២_៥_០១.

បានឃើញសារណាតបរបស់លោក គុប សារុន ចុះថ្ងៃទី០៥_៧_០១ .

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា:_សាលដីកាសាលាឧទ្ធរណ៍ដែលសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

បានស្តាប់ចម្លើយរបស់លោក ស៊ិន កេវ ដែលតំណាងទាំងពីរបានប្រគល់សិទ្ធិអោយឆ្លើយនៅពេលសវនាការថា:_សាលាឧទ្ធរណ៍កាត់មិនត្រឹមត្រូវ ដោយកាត់អោយទៅ

បុគ្គល តុប សារុន តែឯង ចំណុចមួយទៀតសំអាងលើសំអាងក៏មិនសមស្របដែរ ។

បានស្តាប់ចម្លើយរបស់លោក តុប សារុន ដែលបានឆ្លើយនៅពេលសវនាការថា:- នៅឆ្នាំ ១៩៩១ ខ្លួនជាអ្នករៀបចំឃ្សៀត្រីនេះ ព្រោះពីមុនខ្លួនជាមន្ត្រីកសិកម្ម បៀ អ៊ួន ជាប្អូនធម៌របស់ខ្លួនជាប្រធានក្រុមហ៊ុនក្នុងការទិញ-លក់ ត្រីនេសាទស្រស់ និងកែច្នៃ មិនមែនប្រគល់ដីអោយទៅក្រុមហ៊ុនទេ ។

ការិយាល័យដលផលមិនបានប្រគល់ដីអោយក្រុមហ៊ុនទេ គឺ ប្រគល់កម្មសិទ្ធិអោយខ្លួន ដូច្នេះខ្លួនជាម្ចាស់ ខ្លួនមានសិទ្ធិលក់ ឯរោងគីឡូងសម័យសង្គ្រាម វាត្រូវខូចខាតអស់ទៅហើយ ។

ការិយាល័យដលផលជាអ្នកសុំដី ប្រគល់អោយអ្នកណាដែលមានច្បាប់ឃ្សៀត្រី ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក មេធាវី ប៊ិច វិច្ឆិកា ការពារក្តីអោយដើមចោទថា:-ការសំរេចផ្តល់ប័ណ្ណកម្មសិទ្ធិអោយលោក តុប សារុន គឺជាកំហុសរបស់មន្ត្រីអំណាចថ្នាក់ក្រោម ។ ការផ្ទេរសិទ្ធិពីលោក ផិត ផានុង ទៅ តុប សារុន ជាការមិនត្រឹមត្រូវទេព្រោះក្រុមហ៊ុនមិនទាន់រលាយ ហើយក៏ពុំមានចំណារពីប្រធានគណៈកម្មាធិការខេត្តដែរ ។

ការផ្តល់ប័ណ្ណកម្មសិទ្ធិរបស់ស្រុកអូរជ្រៅអោយ តុប សារុន ដែលជាសមាជិកក្រុមហ៊ុន ជាការខុសឆ្គង ទាំងស្រុកក៏ទទួលស្គាល់ដែរថាដីជារបស់ក្រុមហ៊ុន ។

ពាក្យសុំកាន់កាប់របស់លោក តុប សារុន ធ្វើក្រោយការប្រកាស ១១ថ្ងៃ ហើយមិនបានចុះកាសែត ឬប្រកាសតាមវិទ្យុ អោយសមាជិកភាគហ៊ុនដទៃទៀតដឹង ។

លោក ឆាយ សាវ៉េត បានចុះហត្ថលេខាលើកំណត់ហេតុវាស់វែងដីថាបានប្រគល់ដីទៅអោយក្រុមហ៊ុន តុប សារុន បានន័យថាមិនមែនប្រគល់អោយបុគ្គល តុប សារុន ទេ ។

ដូច្នេះការសំរេចរបស់សាលាឧទ្ធរណ៍គឺជាការខុសឆ្គង សាលាឧទ្ធរណ៍ក៏យល់ឃើញដែរថាដីនេះជារបស់ក្រុមហ៊ុន មិនមែនរបស់តុប សារុនទេ ។

ដី និង ស្តង់ឃ្សៀត្រីនៅប៉ោយប៉ែត ជារបស់ក្រុមហ៊ុន មិនមែនជារបស់លោក តុប សារុន ទេ ។

សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ និង សុំបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍វិញ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក មេធាវី ទូត លុច ការពារក្តីអោយចុង-ចម្លើយថា៖- លោក តុប សារុន ត្រួតត្រាងទីតាំងនោះដោយយកកន្លែងនោះធ្វើជាកន្លែងកោសប្រហិត នេះមិនមែនជាការរកស៊ីរបស់ក្រុមហ៊ុនទេ ។

ដើមចោទមិនបានប្តឹងឧទ្ធរណ៍ពីសាលក្រមរបស់តុលាការថ្នាក់ក្រោមទេ ដូច្នេះដើមចោទត្រូវផ្តាច់សិទ្ធិក្នុងការទាមទារដីទំនាស់នេះហើយ ពុំបណ្តឹងសាទុក្ខរបស់ដើមចោទនេះគឺត្រង់ចំណុចសំអាងលើសំអាងលើដីតែប៉ុណ្ណោះ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវី នៃ គូភាគី ។
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី ០៥ ខែ មិនា ឆ្នាំ ២០០១ របស់អ្នកស្រី ហៀ អ៊ួន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី។

- យល់ឃើញថា ភាគីដើមចោទអ្នកស្រី ហៀ អ៊ួន ពុំបានប្តឹងឧទ្ធរណ៍ ពីការដែលតុលាការខេត្តបន្ទាយមានជ័យ សំរេចប្រគល់ដីទំនាស់អោយទៅអាជ្ញាធរខេត្តដែលជា[illegible]ទេ ដូច្នេះអ្នកស្រីរូបនេះពុំមានសិទ្ធិប្តឹងសាទុក្ខដើម្បីទាមទារដីនេះទៀតឡើយ។ ហើយក៏ពុំបានប្តឹងឧទ្ធរណ៍អំពីសំណងដែលក្រុមហ៊ុនអ្នកស្រីត្រូវបានទទួលដែរ ។ ចំពោះបណ្តឹងតវ៉ាចុះថ្ងៃទី ១៩-៤-០០ របស់លោក ឆ ប៊ុនរិទ្ធី ពីចំណុចទី៣ នៃ សាលក្រមនោះធ្វើឡើងពុំត្រឹមត្រូវតាមទម្រង់ នៃ បណ្តឹងឧទ្ធរណ៍ឡើយ ដែលតុលាការកំពូលពុំមានសមត្ថកិច្ចពិចារណាទេ ។

- យល់ឃើញថា ទោះបីមានពាក្យប្តឹងតវ៉ាទាមទារដីនេះក៏ដោយ ក៏មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាដីនេះជាទ្រព្យសម្បត្តិឯកជនរបស់ខេត្ត ហើយក្រុមហ៊ុន យៀវ ត្រីរបស់អ្នកស្រី ហៀ អ៊ួន គ្រាន់តែបោះទីតាំងលើដីនេះតាមកិច្ចសន្យា ២ឆ្នាំម្តងតែប៉ុណ្ណោះ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចបន្ថយសំណងពី ៥០លានរៀល មក ៤០លានរៀល ដែលទូទាត់ជាមួយនឹងរោង១ដែលក្រុមហ៊ុនត្រូវរុះរើចេញនោះជាការសមរម្យហើយ ។

- យល់ឃើញថា អាជ្ញាធរខេត្តបន្ទាយមានជ័យ ក៏បានសុំដកខ្លួនពីរឿងក្តីនេះក្នុងនាមជាតតិយជនដែរ ដូច្នេះសាលដីកាលេខ ០៤ "យ" ចុះថ្ងៃទី ១១-០១-០១ មានលក្ខណៈស្ថាពរហើយ ។

## ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី ។

១-ទទួលបណ្តឹងសាទុក្ខលេខ ៥៨ ចុះថ្ងៃទី០៥ ខែ មិនា ឆ្នាំ ២០០១ របស់អ្នកស្រី ហៀ អ៊ួន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៤ "យ" ចុះថ្ងៃទី ១១-០១-០១ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣_រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០រ,០០ ដែលអ្នកស្រី ហៀង អ៊ិនបានបង់រួចហើយ គឺ :_

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៥.៦០០រ,០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ,០០ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

-ចំណាយក្នុងកិច្ចប្រគល់ដីការកោះចំនួន ១៥.០០០រ,០០ សរុប ១៩.០០០រ,០០ ។

- បង្គាប់អោយលោក តុប,សារុន បង់ពន្ធសមាមាត្រលើទឹកប្រាក់៥០លានរៀល ដែលត្រូវសងទៅក្រុមហ៊ុនអ្នកស្រី ហៀង អ៊ិន ។

- បង្គាប់អោយក្រុមហ៊ុនអ្នកស្រី ហៀង អ៊ិនបង់ពន្ធសមាមាត្រ១ភាគរយលើតម្លៃដីទំនាស់ជាក់ស្តែង ។

៤_សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២១_ខែ កុម្ភៈ ឆ្នាំ ២០០២ ។